**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# លិខិតធានាអះអាង

ឈ្មោះ សី សៀវ ម៉េញ ភេទ ស្រី ដែលកាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ 011296411 អាសយដ្ឋានផ្ទះលេខ............ភូមិ គោកឃ្លាំង ឃុំ/សង្កាត់ ភ្នំពេញថ្មី ស្រុក/ខណ្ឌ សែនសុខ រាជធានី/ខេត្ត ភ្នំពេញ តួនាទីជា ប្រធានផ្នែករដ្ឋបាល នៅ [illegible] ពិតជាបានទទួលការណែនាំពីការរៀបចំលិខិតស្នើសុំព្យួរកិច្ចសន្យាការងារ និងបញ្ជីរាយនាមកម្មករនិយោជិត ពីមន្ត្រីឈ្មោះ **នួន កុសល្យ** ភេទប្រុស ដែលមានអត្តលេខការងារ **១៩៥១២០០១០៣** របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដូចខាងក្រោម៖

១-ការដាក់លិខិតស្នើសុំព្យួរកិច្ចសន្យាការងារតាមទម្រង់ដែលបានកំណត់ ទៅនាយកដ្ឋានអធិការកិច្ចការងារ ដោយភ្ជាប់មកជាមួយនូវ៖

- បញ្ជីបើកប្រាក់ឈ្នួលចុងក្រោយមុនពេលស្នើសុំព្យួរកិច្ចសន្យាការងារ
- កិច្ចព្រមព្រៀងរវាងកម្មករនិយោជិតជាមួយនិយោជក ចំនួន ៣ ច្បាប់
- វិញ្ញាបនបត្រពាណិជ្ជកម្ម/អាជីវកម្ម (ថតចម្លង) ចំនួន ៣ ច្បាប់
- ប័ណ្ណពន្ធប៉ាតង់ (ថតចម្លង) ចំនួន ៣ ច្បាប់
- វិញ្ញាបនបត្របញ្ជិកាសហគ្រាស គ្រឹះស្ថាន ក្នុង ប.ស.ស. ចំនួន ៣ ច្បាប់

២-ការរៀបចំបញ្ជីរាយនាមកម្មករនិយោជិតដែលស្នើសុំព្យួរកិច្ចសន្យាការងារចំនួន ៣ ច្បាប់ និងផ្ញើជា Soft Copy តាមទម្រង់ MS Excel មកកាន់ Email: suspension@nea.gov.kh ហើយត្រូវមានទិន្នន័យដូចខាងក្រោម៖

- ឈ្មោះកម្មករនិយោជិត/ភេទ/ថ្ងៃខែឆ្នាំកំណើត/បម្រើការនៅផ្នែក
- លេខប័ណ្ណសមាជិកប.ស.ស/លេខរៀងក្នុងបញ្ជីកម្មករនិយោជិតដែលបានធ្វើបច្ចុប្បន្នភាពមកក្រសួង
- លេខអត្តសញ្ញាណប័ណ្ណ
- លេខទូរស័ព្ទ (ផ្ទាល់ខ្លួន)
- ស្នាមមេដៃស្តាំ

៣-ការបោះត្រាក្រុមហ៊ុននៅគ្រប់ទំព័រនៃបញ្ជីរាយនាមកម្មករនិយោជិតដែលស្នើសុំព្យួរកិច្ចសន្យាការងារ

៤-ការទទួលខុសត្រូវបង់ជូនកម្មករនិយោជិតនូវប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល ចំនួន ៤០ដុល្លារអាមេរិក ក្នុង១ខែ ក្នុងករណីមិនបានផ្សព្វផ្សាយ និងមិនបានតម្រូវឱ្យកម្មករនិយោជិតផ្តល់លេខអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងលេខទូរស័ព្ទ ដែលខ្លួនបានចងក្រងរួច និងផ្តិតស្នាមមេដៃបញ្ជាក់។

៥-ក្រុមហ៊ុនបានប្រាប់កម្មករនិយោជិតឱ្យទិញលេខទូរស័ព្ទ (ករណីគ្មានលេខទូរស័ព្ទ) ហើយនឹងកាត់បញ្ជីឈ្មោះកម្មករនិយោជិតទាំងឡាយណាដែលមិនមានលេខអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងលេខទូរស័ព្ទ ចេញពីបញ្ជីឈ្មោះកម្មករនិយោជិតដែលត្រូវស្នើសុំព្យួរកិច្ចសន្យាការងារ។

ខ្ញុំក្នុងនាមនិយោជក បានយល់និងឯកភាពគោរពតាមការណែនាំដូចមានខាងលើ នៅចំពោះមុខអធិការការងារ និងសូមប្តេជ្ញាចិត្តអនុវត្តតាមការណែនាំរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងសូមទទួលខុសត្រូវចំពោះមុខច្បាប់ លើការធានាអះអាងនេះ។

ថ្ងៃទី៤ ខែមេសា ឆ្នាំ២០២៣

| **តំណាងនិយោជក** | **អធិការការងារ** |
|---|---|
| **ស្នាមមេដៃស្តាំ** | **ស្នាមមេដៃស្តាំ** |
| សី សៀវម៉េញ | **នួន កុសល្យ** |